# ពើងឆត្រ

ពើងឆត្រ ស្ថិតនៅជើងភ្នំគូលែនភាគខាងកើតឈៀងខាងជើងមានចម្ងាយប្រមាណ ១២គីឡូម៉ែត្រពីទីរួមស្រុកស្វាយលើ។ ដែលមានទីតាំងភូមិសាស្រ្តស្ថិតនៅភូមិក្រញូង ឃុំតាសៀម ស្រុកស្វាយលើខេត្តសៀមរាប ដែលមានចំនុចនិយាមការ X 413267 Y 1503576។ ភ្នំគូលែន ជាអតីរាជធានីដ៏ចំណាស់ស្ថិតក្នុងសម័យអង្គរ ដោយបច្ចុប្បន្នជាឧទ្យានជាតិព្រះបាទជ័យវរ្ម័ន នរោត្តម ភ្នំគូលែន។ ភ្នំគូលែន ជាទីតាំងដ៏ពិសិដ្ឋមួយដែលបណ្តុំដោយជំនឿផ្សេងៗ និងជាកន្លែងដែលពោរពេញដោយសិល្បៈចំរុះ និងប្លែកៗ (រូបលេខ១)។[1]

ពើងឆត្រជាពើងធម្មជាតិ ដែលមានផ្នែកខាងក្រោមតូច និងរីកធំនៅផ្នែកខាងលើ។ វាមានទំហំប្រមាណ២០ម៉ែត្រ(រូបលេខ២) និងមានទៅដោយពើងថ្មជាច្រើនផងដែរនៅតំបន់នេះ។ គូលែនដែលជាអតីរាជធានី និងជាទីកន្លែងនៃជំនឿផ្សេងៗ កន្លែងដែលពោរពេញដោយសិល្បៈចំរុះ និងប្លែកៗ។ នៅក្បែរនោះក៏មានបុរាណស្ថានមួយហៅថាពើងព្រះពុទ្ធក្រោមផងដែរ។ ពើងថ្មដែលត្រូវបានគេប្រើប្រាស់នោះជាទីតាំងសម្រាប់អ្នកបួស ឬអ្នកសំណាក់ធម៌ ទាំងផ្នែកព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា តាំងពីបុរាណរហូតមកដល់ពេលបច្ចុប្បន្ន ក៏យើងនៅប្រទះឃើញមានផងដែរ។ ស្នាដៃសិល្បៈមួយចំនួនក៏អាចកំណត់អាយុកាលបាន និងខ្លះក៏ពិបាកក្នុងការកំណត់អាយុកាលផងដែរ។

ពើងឆត្រត្រូវបានអ្នកស្រុកនៅតំបន់នេះ ហៅឈ្មោះទៅតាមរូបចម្លាក់មួយដែលបានឆ្លាក់នៅផ្នែកខាងលើ នៃពើងថ្ម ដែលអ្នកស្រុកហៅថាឆត្រ។ ចម្លាក់នេះជាក្បាច់ផ្កាឈូកដែលមានសណ្ឋានចំនួន៨ត្របករាងមូល ទំហំប្រមាណ៨០ស.ម។ ក្បាច់ចម្លាក់នេះប្រកបដោយភាពស្រស់ស្អាត និងផ្ចិតផ្ចង់កំរិតខ្ពស់ផងដែរ (រូបលេខ៣)។ តែនៅផ្នែកកណ្តាលនៃចម្លាក់ត្រូវបានគេលួចដាប់បាត់ទៅហើយ។ បើតាមមន្រ្តីឧទ្យានុរក្សនៅទីនោះ បានរៀបរាប់ថា នៅផ្នែកកណ្តាលមានរូបមនុស្សពីរនាក់ជិះគោ នេះអាចថាជារូបព្រះសិវៈ និងព្រះនាងឧមា ជិះគោនន្ទីន។ ចម្លាក់ប្រភេទនេះដែលមានរូបជាផ្កាឈូក ក៏ឃើញមាននៅទីតាំងមួយចំនួននៃភ្នំគូលែនផងដែរ ដូចជានៅពើងឆ័ត្រឥសី តែត្រូវបានឆ្លាក់នៅផ្នែកខាង

[1] ក្រសួងបរិស្ថាន ២០១៩:៨៩

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

AMS អរិយធម៌ខ្មែរ

ក្រោមទៅវិញ។ ចំណែកនៅទីតាំងមួយទៀតដែលស្ថិតនៅភ្នំត្បែង ខេត្តព្រះវិហារ ត្រង់ចំនុចថ្ម៣ដុំ គេហៅថាពើងខែ ក៏មានចម្លាក់លក្ខណៈប្រហាក់ប្រហែល និងរូបនេះដែរ តែមានលំអដោយលំពែងត្រីសូលជាមួយផង នេះប្រហែលជាបញ្ជាក់អំពីការគោរពចំពោះព្រះឥសូរផងដែរ។ ម្យ៉ាងទៀតទីតាំងនេះ ក៏មានសិលាចារឹកចារជាភាសាសំស្ក្រឹត និយាយពីការគោរពចំពោះព្រះឥសូរប្រហែលក្នុងសតវត្សទី១០ នៃគ.ស.។

ពើងឆត្រ បានរកឃើញនៅវត្ថុសិល្បៈមួយចំនួនដូចជា ជើងទម្រ សាណាទ្រូនីដំកល់លិង្គព្រះឥសូរ(រូបលេខ២)។ នេះអាចបញ្ជាក់ថាទីតាំងនេះ ជាទីតាំងនៃអ្នកគោរពបូជាចំពោះព្រះឥសូរ។ យើងក៏បានរកឃើញបំណែកសិលាចារឹកមួយផ្នែកតូច មានលំនាំជាទម្រង់អក្សរអាចក្នុងអំឡុងសតវត្សទី១០ និង១១ នៃគ.ស. ប្រហែលត្រូវបានចារជាភាសាសំស្ក្រឹតផងដែរ តែផ្នែកដើមនៃសិលាចារឹកមិនដឹងនៅទីណានោះទេ(រូបលេខ៥) ។ សិលាចារឹកនេះប្រហែលមិនទាន់បានចុះបញ្ជីនៅឡើយទេ ហើយយើងក៏មិនដឹងថាវាស្ថិតនៅទីតាំងដើមឬយ៉ាងណា?

អ្វីដែលជាលក្ខណៈពិសេសមួយនៅពើងឆត្រនេះ គឺមានវត្ថុជាតុដើមមួយចំនួនដែលងាយស្រួលនឹងសង់សំណង់របស់អ្នកបួស ដោយសំណង់ទាំងនោះ យើងឃើញមានសំណង់សាងអំពីដីឥដ្ឋ ឬដីដំបូក យកទៅបូកនៅលើថ្មដុំៗ បង្កើតជាបន្ទប់តូចៗ និងពង្រីកឃឿននៅក្រោមពើងថ្ម (រូបលេខ៦)។ សំណង់ដីឥដ្ឋ ឬដីដំបូកទាំងនោះ បានចែកជាបន្ទប់តូចៗ ដូចជាទីតាំងមានក្បាច់ផ្កាឈូក បន្ទប់តូចៗផ្នែកខាងក្រោយ និងខាងផ្នែកក្រោមនៃពើង (រូបលេខ៧-៨)។ សំណង់របៀបនេះ យើងឃើញមានសំបូរច្រើនក្នុងពើងជាច្រើននៃតំបន់ភ្នំគូលែន និងក៏ឃើញប្រើប្រាស់ជាសាងសង់ផ្ទះ ឬជម្រុកស្រូវផ្សេងៗផងដែរ។

រួមសេចក្តីមកយើងអាចយល់ថា ទីតាំងពើងឆត្រនេះ ជាទីតាំងនៃពពួកព្រាហ្មណ៍ដែលមកធ្វើសម្មាធិ ឬតបៈធម៌ ដែលពួកគាត់គោរពចំពោះព្រហ្មញ្ញសាសនា និកាយព្រះឥសូរ អាចក្នុងអំឡុងរវាងសតវត្សទី១០ ទៅ១១គ.ស រហូតមកដល់បច្ចុប្បន្ន។ ហើយសំណង់ជាបន្ទប់តូចៗ គឺពពួកព្រាហ្មណ៍សង់សម្រាប់ជាជម្រកក្នុងការសម្មាធិ ឬក៏អាចសំណង់សម្រាប់ប្រជាជនប្រើប្រាស់ជាជម្រកការពារទឹកភ្លៀង និងអាចការពារសត្វសា

ហាវមួយចំនួន កំឡុងពេលដែលពួកគេចូលទៅក្នុងព្រៃផងដែរ។ ទីតាំងនេះ នៅមិនឆ្ងាយប៉ុន្មានទេពីផ្លូវបុរាណដែលមានចំងាយប្រមាណ៨គីឡូម៉ែត្រ។




រូបលេខ១



អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

រូបលេខ២



រូបលេខ៣



អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

រូបលេខ២



រូបលេខ៥



អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

រូបលេខ៦



រូបលេខ៧



អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

*រូបលេខ២៨*

## ឯកសារយោង

ក្រសួងបរិស្ថាន

២០១៥, បញ្ជីបុរាណស្ថានក្នុងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្ត ភ្នំគូលែន, ទំព័រ៨៥